SILAKA

# ឯកសារពិស្តារ

## ម៉ូឌុល ២

# [illegible]



# ម៉ូឌុល ២៖ ទស្សនាទាននៃគណនេយ្យភាពសង្គម

៙៙✵៚៚

**ទំព័រ**


១. និយមន័យគណនេយ្យភាព និងគណនេយ្យភាពសង្គម ........ ២

១.១ តើអ្វីជាគណនេយ្យភាព? ........ ២

១.២ តើគណនេយ្យភាពសង្គមជាអ្វី? ........ ៣

២. តើគណនេយ្យភាពសង្គម មានសារៈសំខាន់អ្វីខ្លះ? ........ ៤

៣. មូលដ្ឋានគ្រឹះនៃគណនេយ្យភាពសង្គម ........ ៥

៤. កត្តាគាំទ្រឱ្យគណនេយ្យភាពសង្គមអនុវត្តប្រកបដោយជោគជ័យ ........ ៦

៥. ទំនាក់ទំនងរវាងគណនេយ្យភាពសង្គម វិមជ្ឈការ និងអភិបាលកិច្ចល្អ ........ ៩

៦. យន្តការ ឬ ឧបករណ៍គណនេយ្យភាពសង្គម ........ ១០

# គណនេយ្យភាពសង្គម

## ១. និយមន័យគណនេយ្យភាព និងគណនេយ្យភាពសង្គម

### ១.១ តើអ្វីជាគណនេយ្យភាព?

គណនេយ្យភាព គឺជាកាតព្វកិច្ចរបស់អ្នកកាន់អំណាចត្រូវទទួលយក ឬទទួលខុសត្រូវរាល់សកម្មភាព ដែលបានប្រព្រឹត្ត។ "**អ្នកកាន់អំណាច**" សំដៅដល់អ្នកទាំងឡាយដែល មានឥទ្ធិពលផ្នែកនយោបាយ ហិរញ្ញវត្ថុ ឬទម្រង់ផ្សេងៗនៃអំណាច រួមមានមន្ត្រីក្នុងជួររដ្ឋាភិបាល សាជីវកម្មឯកជន ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងអង្គការសង្គមស៊ីវិល ដែលមន្ត្រីទាំងឡាយត្រូវមានគណនេយ្យភាពចំពោះ ទី(១) ក្រមសីលធម៌និង ទី(២)ទង្វើរបស់ខ្លួន....។ និយាយម្យ៉ាងទៀតគឺមន្ត្រីទាំងឡាយត្រូវ (១) គោរពច្បាប់ និងមិនរំលោភអំណាចដែលផ្តល់ឱ្យហើយ (២)បម្រើប្រយោជន៍សាធារណៈប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល និងដោយយុត្តិធម៌។

គណនេយ្យភាពអាចត្រូវត្រួតពិនិត្យដោយភាគីពីរគឺ "ភាគីផ្តល់ឱ្យ" និង "ភាគីទទួល"។

**ក)** "ភាគីផ្តល់ឱ្យ-ខាងក្នុង ឬ **ខ្សែបណ្តោយ**"

ប្រទេសនីមួយៗបានដាក់ចេញនូវទម្រង់យន្តការមួយចំនួន ឱ្យចំត្រឹមត្រូវដើម្បីលើកកម្ពស់ និងធានាឱ្យមានគណនេយ្យភាពរបស់មន្ត្រីសាធារណៈ។ ប្រព័ន្ធយន្តការគណនេយ្យភាពធ្វើឡើងនៅផ្ទៃក្នុងរបស់រដ្ឋ ដែលតែងតែហៅថា "យន្តការគណនេយ្យភាពខ្សែបណ្តោយ" (Schedler et at.1999)។ យន្តការទាំងនេះរួមមានៈ **(១) យន្តការ នយោបាយត្រួតពិនិត្យ និងផ្ទៀងផ្ទាត់** (ឧទាហរណ៍ដូចជាៈលក្ខខណ្ឌរដ្ឋធម្មនុញ្ញ ការបែងចែកអំណាច គណៈកម្មាធិការ ស៊ើបអង្កេតអង្គនីតិបញ្ញត្តិ និងគណៈកម្មាធិការស៊ើបអង្កេតការតាក់តែងច្បាប់...) **(២) យន្តការហិរញ្ញវត្ថុ** (ឧទាហរណ៍ដូចជាៈប្រព័ន្ធសវនកម្មផ្លូវការ និងប្រព័ន្ធគណនេយ្យហិរញ្ញវត្ថុផ្លូវការ...) **(៣) យន្តការរដ្ឋបាល** (ឧទាហរណ៍ដូចជាៈ ការរាយការណ៍តាមឋានានុក្រម បទបញ្ញត្តិហាមប្រាមរបស់មន្ត្រីសាធារណៈ ក្រមសីលធម៌របស់មន្ត្រីសាធារណៈ បទបញ្ជា និងដំណើរការផ្សេងៗដើម្បីឱ្យមានតម្លាភាព និងការឃ្លាំមើលជាសាធារណៈជាដើម) និង **(៤) យន្តការផ្លូវច្បាប់** (ឧទាហរណដូចជាៈ ភ្នាក់ងារត្រួតពិនិត្យអំពើពុករលួយ មន្ត្រីតាមដានមុខងារ សាធារណៈ និងប្រព័ន្ធតុលាការ)(Goetz and Gavanta,2001)។ យន្តការទាំងនេះមានលក្ខណៈពីលើចុះក្រោម ។

### ខ) ខ្សែទទឹង (ភាគីទទួល- ខាងក្រៅ)

ភាគីទទួលសេវា ក៏អាចធ្វើឱ្យមន្ត្រីសាធារណៈមានគណនេយ្យភាពបានដែរ តាមរយៈយន្តការ **ពីក្រោម ទៅលើ**ដោយទាមទារ/បញ្ចេញសំឡេងពីថ្នាក់មូលដ្ឋាន ដែលមានន័យថាយន្តការខ្សែទទឹង ។ គណនេយ្យភាពតាម ខ្សែទទឹងមានន័យជាប្រជាពលរដ្ឋធម្មតា ប្រព័ន្ធផ្សព្វផ្សាយ និង/ឬអង្គការសង្គមស៊ីវិលអនុវត្តដើម្បីឱ្យមន្ត្រីសាធារណៈ បំពេញការងារឱ្យបានល្អស្របតាមបទដ្ឋានដែលកំណត់។

### ១.២ តើគណនេយ្យភាពសង្គមជាអ្វី?

**គណនេយ្យភាពសង្គម** ជាមធ្យោបាយទាំងឡាយណា ដែលអនុវត្តដោយប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិល ដើម្បីជួយរដ្ឋាភិបាល ឬអ្នកផ្តល់សេវាកម្មសាធារណៈ មានគណនេយ្យភាព (ការទទួលខុសត្រូវខ្ពស់) តម្លាភាព និងការឆ្លើយតបនូវ សេចក្តីត្រូវការរបស់សហគមន៍ ដោយមានការសម្របសម្រួល ពីអាជ្ញាធរ អង្គការសង្គមស៊ីវិល ប្រព័ន្ធផ្សព្វផ្សាយ អ្នកពាក់ព័ន្ធផ្សេងៗ។ ធនាគារពិភពលោក បានកំណត់ន័យៈគណនេយ្យភាពសង្គមថាជាវិធីសាស្ត្រ ឆ្ពោះទៅរកការកសាងគណនេយ្យភាពដែលផ្អែកទៅលើការចូលរួមយ៉ាងខ្ជាប់ខ្ជួនរបស់ពលរដ្ឋ (ឧទា. ពលរដ្ឋ សាមញ្ញ និង/ឬអង្គការសង្គមស៊ីវិល)ដែលចូលរួមដោយផ្ទាល់ ឬមិនផ្ទាល់ ដើម្បីឱ្យរដ្ឋាភិបាលមានគណនេយ្យភាពពិតប្រាកដ។

**ដូចនេះ គណនេយ្យភាពសង្គម** សំដៅដល់សកម្មភាព និងយន្តការជាច្រើនបែបយ៉ាង (លើសពីការបោះឆ្នោត) ដែលប្រជាពលរដ្ឋ សហគមន៍ អង្គការសង្គមស៊ីវិល និងប្រព័ន្ធ ផ្សព្វផ្សាយឯករាជ្យនានា អាចប្រើដើម្បីទាមទារឱ្យមន្ត្រី សាធារណៈ និងអ្នកផ្តល់សេវាមានគណនេយ្យភាព។




យន្តការគណនេយ្យភាពសង្គម ជាយន្តការសហការគ្នា រវាងរដ្ឋនិងពលរដ្ឋ។ ពោលគឺ បំពេញឱ្យគ្នាទៅវិញទៅមករវាង យន្តការគណនេយ្យភាពរបស់ (រដ្ឋ) "ផ្នែកខាងក្នុង" និង"ផ្នែកខាងក្រៅ"។ លទ្ធផល និងចីរភាពនោះគឺ

របស់គណនេយ្យភាពសង្គម គឺពេលដែលយន្តការគណនេយ្យភាពសង្គមធ្វើស្ថាបនីយកម្ម ឬ នៅពេលដែលយន្តការគណនេយ្យភាព "ផ្ទៃក្នុង" របស់រដ្ឋ កាន់តែមានតម្លាភាព និងបើកទូលាយឱ្យមានការចូលរួម ខ្ជាប់ខ្ជួនពីប្រជាពលរដ្ឋ។

## ២. តើគណនេយ្យភាពសង្គម មានសារៈសំខាន់អ្វីខ្លះ?

មានការយល់ឃើញធំៗ ៣ ដែលបង្ហាញពីសារៈសំខាន់នៃគណនេយ្យភាពសង្គមគឺ **ធ្វើឱ្យប្រសើរឡើងនូវ អភិបាលកិច្ច បង្កើនប្រសិទ្ធភាពនៃការអភិវឌ្ឍ និងការផ្តល់សិទ្ធិអំណាចដល់ប្រជាពលរដ្ឋ**។ ចំណុចនីមួយៗ នឹងលើក មកពិភាក្សាដូចខាងក្រោម។

ជាដំបូងបង្អស់ គឺការបង្កើននូវ**អភិបាលកិច្ច** គណនេយ្យភាពរបស់មន្ត្រីសាធារណៈជាចំណុចសំខាន់របស់ រដ្ឋាភិបាលល្អមួយ និងតម្រូវការចំបងឱ្យលទ្ធិប្រជាធិប្បតេយ្យមានប្រសិទ្ធភាព។ យន្តការគណនេយ្យភាពសង្គមអាចឱ្យប្រជាពលរដ្ឋសាមញ្ញមានលទ្ធភាពទទួលបានព័ត៌មាន លើកឡើងនូវតម្រូវការរបស់គាត់ និងទាមទារឱ្យមន្ត្រីដែលបានជាប់ឆ្នោតមានគណនេយ្យភាព។ គណនេយ្យភាពសង្គមពង្រឹងសមត្ថភាពប្រជាពលរដ្ឋមិនឱ្យធ្វើការទាមទារដោយការប្រឆាំង ប៉ុន្តែ ដោយការចូលរួមជាមួយមន្ត្រីជំនាញ និងអ្នកនយោបាយ ដែលអនុវត្តសកម្មភាពដោយ មានការផ្តល់ព័ត៌មាន ឬការជូនដំណឹងជាមុនមានការរៀបចំត្រឹមត្រូវ មានលក្ខណៈស្ថាបនា និងលក្ខណៈជាប្រព័ន្ធ ដើម្បីបង្កើនឱ្យមាន ឱកាស ធ្វើការផ្លាស់ប្តូរវិជ្ជមាន។

គណនេយ្យភាពសង្គមអាចរួមចំណែកឱ្យ **ការអភិវឌ្ឍន៍មានប្រសិទ្ធភាព**។ គេអាចសម្រេចបានតាមរយៈ ការធ្វើឱ្យប្រសើរឡើងដល់ការផ្តល់សេវាសាធារណៈ និងការរៀបចំគោលនយោបាយ។ តាមរយៈព័ត៌មាន និងការ ពង្រឹងការបញ្ចេញមតិរបស់ប្រជាពលរដ្ឋការជំរុញឱ្យមានការពិភាក្សា និងការប្រជុំរវាងអ្នកពាក់ព័ន្ធសំខាន់ទាំងបី (ស្ថាប័នសាធារណៈ អ្នកផ្តល់សេវា និងប្រជាពលរដ្ឋ) និងការបង្កើតឱ្យមានការលើកទឹកចិត្តចំពោះទង្វើប្រសើរ ណាមួយ នោះយន្តការគណនេយ្យភាពសង្គមនឹងធ្វើឱ្យប្រសើរឡើងដល់ប្រសិទ្ធភាពនៃការផ្តល់សេវានិងធ្វើការ សម្រេចចិត្តលើកិច្ចការសាធារណៈ កាន់តែមានតម្លាភាព មានការចូលរួម និងឆ្លើយតបទៅនឹង តម្រូវការពលរដ្ឋក្រីក្រ។

ចុងក្រោយគណនេយ្យភាពសង្គម **អាចនាំឱ្យមានការផ្តល់ភាពអង់អាចដល់ ពលរដ្ឋ** ពិសេសដល់ ពលរដ្ឋក្រី ក្រ។ ពាក្យថា **ការផ្តល់ភាពអង់អាច** មានអត្ថន័យទូលំទូលាយ យើងអាចនិយាយបានថាជាការពង្រឹងសេរីភាព នៃ ការជ្រើសរើស និងការអនុវត្តសកម្មភាព។ ឱកាសនៃការបញ្ចេញមតិនេះបានពង្រឹងសិទ្ធិអំណាចដល់ពលរដ្ឋក្រីក្រ និងធ្វើឱ្យរដ្ឋាភិបាលកាន់តែមានការឆ្លើយតប។ មានន័យថាប្រជាពលរដ្ឋក្រីក្រមានសិទ្ធិអំណាចនិងទទួល បានការគាំទ្រ ក្នុងការអនុវត្តសកម្មភាពគណនេយ្យភាពសង្គមរបស់គាត់ និងធានាថាយន្តការទាំងនោះរៀបចំសម្រាប់ជា ប្រយោជន៍ របស់គាត់

(មិនមានត្រួតត្រាដោយអ្នកមានអំណាចនោះទេ) បញ្ហាប្រឈមត្រូវពិចារណាគឺការអនុវត្ត គណនេយ្យភាពសង្គមរបស់អ្នកក្រីក្រ។

**រូបទី ១ : ហេតុអ្វីបានជាគណនេយ្យភាពសង្គមមានសារៈសំខាន់?**




## ៣. មូលដ្ឋានគ្រឹះនៃគណនេយ្យភាពសង្គម

គណនេយ្យភាពសង្គម ជាសំណុំសកម្មភាព ហេតុនេះហើយវាត្រូវការ គោលការណ៍ជាមូលដ្ឋានឬសមាសធាតុគាំទ្រជាច្រើន ដូចជា (១) **ការទទួលបានព័ត៌មាន** (២) **ការបញ្ចេញមតិរបស់ពលរដ្ឋ** និង (៣) **ការភ្ជាប់ទំនាក់ទំនង** ប្រជាពលរដ្ឋក្នុងដំណើរការចរចារធ្វើឱ្យមានភាពប្រសើរឡើង។

> មូលដ្ឋានគ្រឹះនៃគណនេយ្យភាពសង្គមរួមមាន (១) ការទទួលបានព័តិមាន (២) ការបញ្ចេញមតិរបស់ពលរដ្ឋ និង(៣) ការភ្ជាប់ទំនាក់ទំនង ប្រជាពលរដ្ឋក្នុងដំណើរការចរចាធ្វើឱ្យមានភាពប្រសើរឡើង។

**ការទទួល និងប្រមូលព័ត៌មានព្រមទាំងផ្សព្វផ្សាយជាសាធារណៈ**: ជាគន្លឹះសំខាន់នៃគណនេយ្យភាពសង្គម។ ការរៀបចំជាភស្តុតាងដែលមានភាពជឿជាក់ ត្រឹមត្រូវ ជា រឿយៗ ដើម្បីធ្វើឱ្យមន្ត្រីសាធារណៈមានគណនេយ្យភាព ទទួល បាន និងយកមកវិភាគទិន្នន័យ/ព័ត៌មាន ដែលផ្តល់ដោយ "**ភាគីផ្តល់ឱ្យ**" (មានរដ្ឋាភិបាល និងអ្នកផ្តល់សេវា) និង**ភាគី ទាមទារ**" (អ្នកប្រើ ប្រាស់សេវារបស់រដ្ឋាភិបាល សហគមន៍ និង ប្រជាពលរដ្ឋ)។ តម្លាភាពរបស់រដ្ឋាភិបាល និង សមត្ថភាព របស់ខ្លួនក្នុងការរៀបចំ និងផ្តល់ទិន្នន័យ

និងគណនី ជាកត្តា សំខាន់ក្នុងការទទួល បានព័ត៌មានពីភាគីផ្តល់ឱ្យ (ដូចជា កម្មវិធីនយោបាយ ថវិកាដែលត្រូវទូរទាត់ និងគណនី កំណត់ ត្រាពីធនធាន លទ្ធផល និងប្រាក់ចំណាយ របាយ-ការណ៍សវនកម្ម ។ល។...)។ ចំណុចឬគោលបំណងដែលគណ នេយ្យភាពសង្គមផ្តោតជាសំខាន់នោះគឺការបញ្ចុះបញ្ចូល ឬចរចារដើម្បីលើកកម្ពស់សិទ្ធិទទួលបានព័ត៌មាន និងតម្លាភាព ជាសាធារណៈ។ ចំពោះ ព័ត៌មានពី "ភាគីទាមទារ" វិញទទួលបានតាមរយៈវិធីសាស្ត្រនិងឧបករណ៍បែបចូលរួម (ដូចជាបានពី ប័ណ្ណដាក់ពិន្ទុ សហគមន៍ របាយការណ៍មតិប្រជាពលរដ្ឋ ការពិនិត្យតាមដាន និងវាយតម្លៃដោយ មានការចូលរួមជាដើម) បានអនុវត្ត ដើម្បីប្រមូលទិន្នន័យនៅពេលដែលប្រើ ដែលជានិច្ចកាល ដើម្បីលើកកំពស់ ចំណេះ ដឹង និងជំរុញការកៀរគរ និងរៀចំនៅថ្នាក់មូលដ្ឋាន។

សមាសធាតុសំខាន់មួយទៀតរបស់គណនេយ្យភាពសង្គមគឺការធ្វើប្រជាពលរដ្ឋអាចលើកឡើងនូវមតិយោបល់ សេចក្តីត្រូវការ និងក្តីបារម្ភរបស់គាត់បានចំណុចនេះអាចជួយឱ្យរដ្ឋាភិបាលយល់កាន់តែច្បាស់ពីតម្រូវការ អាទិភាពរបស់ពលរដ្ឋ និងកំណត់នូវវិធានការ ឬដោះស្រាយប្រកបដោយប្រសិទ្ធភាព។ យុទ្ធសាស្ត្រក្នុងការពង្រឹង សំឡេងរបស់ប្រជាពលរដ្ឋ មានដូចជាការបង្កើតឱ្យមានវេទិការពិភាក្សានិងចរចា រវាងរដ្ឋនិងប្រជាពលរដ្ឋ ការបង្កើតទំនុកចិត្តរបស់ពលរដ្ឋ ការលើកកម្ពស់សិទ្ធិ ការសម្របសម្រួលឱ្យមានការចងក្រងក្រុម និងសម្ព័ន្ធប្រជាពលរដ្ឋ ដែលគាត់អាចនិយាយ ដោយចំហ និងមានលក្ខណៈរួម(តែមួយ) ដើម្បីឱ្យយុទ្ធសាស្ត្រទាំងនេះអនុវត្តទៅបាន ត្រូវការជួយជ្រោមជ្រែងពីប្រព័ន្ធផ្សព្វផ្សាយ(ទំនើបនិងបែបប្រពៃណី)។ ការប្រឈមធំបំផុតនៃគណនេយ្យភាពសង្គម គឺការធានាឱ្យពលរដ្ឋក្រីក្រ និងជនគ្មានដំណាងមានមតិយោបល់ដោយសារការលប់លើនៃជន ឬក្រុមដែលមានឥទ្ធិពល។

ការប្រឈមចម្បងបំផុតនៃគណនេយ្យភាពសង្គម គឺការមិនឆ្លើយតបរបស់មន្ត្រីសាធារណៈ និងការធ្វើឱ្យមានភាពប្រសើរឡើងពិតប្រាកដ។ ដំណើរការចរចាត្រូវធ្វើជាបន្តបន្ទាប់ និងជាលក្ខណៈទំលាប់ និងផ្លូវការ។ ដោយអនុវត្តតាមទម្រង់ ការជួបប្រជុំដោយផ្ទាល់ រវាងពលរដ្ឋនិងរដ្ឋាភិបាល ដូចជា ការប្រជុំសហគមន៍ និងការចរចា ឬពិគ្រោះយោបល់ផ្ទាល់។ ក្នុងការចរចាឱ្យមានការផ្លាស់ប្តូរ ក្រុមប្រជាពលរដ្ឋប្រើមធ្យោបាយផ្លូវការ និង ក្រៅផ្លូវការ ក្រោមរូបភាព បញ្ចុះបញ្ចូល ដាក់សំពាធ លើកទឹកចិត្ត និងការដាក់ទណ្ឌកម្ម ដូចជា បង្កើតឱ្យមាន ការដាក់ សំពាធសាធារណៈ (ដូចជាតាមរយៈយុទ្ធនាការសារព័ត៌មាន និងការប្រជុំសាធារណៈ) ឬនៅពេលចាំបាច់ ដោយត្រឡប់មកប្រើប្រាស់មធ្យោបាយផ្លូវការ (ផ្លូវច្បាប់ និងប្រព័ន្ធតុលាការ) ដែលមានលក្ខណៈខុសៗគ្នា ពីប្រទេសមួយទៅប្រទេសមួយ។ ក្នុងបណ្តាប្រទេសជាច្រើនក្រុមប្រជាពលរដ្ឋយល់ឃើញថាកំណែទម្រង់ច្បាប់និងស្ថាប័ន គឺចាំបាច់ក្នុងការសម្របសម្រួលការចរចាប្រកបដោយអត្ថន័យ។

## ៤. កត្តាគាំទ្រឱ្យគណនេយ្យភាពសង្គមអនុវត្តប្រកបដោយជោគជ័យ

ដ្យាក្រាមខាងក្រោមបង្ហាញពី កត្តា៤ សំខាន់ៗដែលនាំឱ្យគណនេយ្យភាពសង្គនអនុវត្តប្រកបដោយជោគជ័យ:

(១) យន្តការភ្ជាប់ទំនាក់ទំនងរវាង ពលរដ្ឋ និងរដ្ឋ

(២) ឥរិយាបថ និងសមត្ថភាព ប្រជាពលរដ្ឋ និងសង្គមស៊ីវិល

(៣) ឥរិយាបថ និងសមត្ថភាព រដ្ឋ ឬ មន្ត្រីសាធារណៈ

(៤) បរិយាកាសអំណោយផល




ចំណុចនីមួយៗត្រូវ ផ្តោតជាសំខាន់លើមូលដ្ឋាន ៣នៃគណនេយ្យភាពសង្គម គឺ ព័ត៌មាន សំឡេងពលរដ្ឋ និងការចរចា ។ ដោយគណនេយ្យភាពសង្គមជាសកម្មភាពដែលសំដៅដល់ការបង្កើត ឬពង្រឹងនូវយន្តការទាំងឡាយ ដើម្បីលើកកម្ពស់គណនេយ្យភាព។ ម្យ៉ាងទៀតត្រូវផ្តោតការយកចិត្តទុក ដាក់លើសកម្មភាពរបស់ រដ្ឋាភិបាល សង្គមស៊ីវិល និង ដៃគូរអភិវឌ្ឍន៍ ឬ អ្នកពាក់ពន្ធ័នានា ដែលអាច

លទ្ធផល ឬឥទ្ធិពល នៃយន្តការគណនេយ្យភាពសង្គម គឺមានឥទ្ធិពលយ៉ាងសំខាន់ពីកត្តានយោបាយ ច្បាប់ វប្បធម៌ និងសេដ្ឋកិច្ច។ ដើម្បីឱ្យលទ្ធផល ឬឥទ្ធិពលរបស់គណនេយ្យភាពសង្គមមានប្រសិទ្ធភាព និងចីរភាព ត្រូវកែសម្រួលវិធីសាស្ត្រផ្សេងៗឱ្យស្របទៅនឹងបរិបទ។

លើកកម្ពស់គណនេយ្យភាពសង្គមតាមរយៈការដោះស្រាយ កត្តានីមួយៗក្នុងចំណោយកត្តាទាំង៤នេះ។ ដើម្បីអនុវត្ត គណនេយ្យភាពសង្គមប្រកបដោយប្រសិទ្ធភាពតម្រូវឱ្យ មានការជួយជ្រោមជ្រែង និងបំពេញបន្ថែម តាមរយៈការ លើកកម្ពស់ ឆន្ទៈ និងសមត្ថភាពរបស់ប្រជាពលរដ្ឋ សង្គមស៊ីវិល និងភ្នាក់ងាររដ្ឋាភិបាល ដើម្បីរួមគ្នាក្នុងសកម្មភាព ធ្វើឱ្យបរិយាកាសអំណោយផលកាន់តែល្អប្រសើរ។

សកម្មភាពគណនេយ្យភាពសង្គមជាច្រើនបានអនុវត្តផ្តោតលើការពង្រឹង ***យន្តការភ្ជាប់ទំនាក់ទំនង-*** យន្តការ ក្នុងការផ្លាស់ប្តូរព័ត៌មាន ពិភាក្សា និងចរចា រវាងប្រជាពលរដ្ឋ និងរដ្ឋាភិបាល។ ចំណុចនេះ តម្រូវឱ្យមានការណែនាំ ឬបង្កើតឧបករណ៍ ឱកាស ឬយន្តការថ្មីៗ សម្រាប់ភ្ជាប់ទំនាក់ទំនងរវាង ប្រជាពលរដ្ឋ និងរដ្ឋាភិបាល ឬត្រូវធ្វើឱ្យ ប្រសើរឡើង កែសម្រួល ឬកំណែទម្រង់ យន្តការ ប្រព័ន្ធ និងភ្នាក់ងារមានស្រាប់។ ឧទាហរណ៍ ការណែនាំ ឬកែសម្រួល ឧបករណ៍ ផ្សព្វផ្សាយព័ត៌មាន របស់រដ្ឋាភិបាល ត្រូវផ្សាយជាសាធារណៈ តាមរយៈការបង្កើតឱ្យមាន មជ្ឈមណ្ឌលផ្សព្វផ្សាយព័ត៌មានសាធារណៈ ឬយុទ្ធនាការផ្សេងៗ បង្កើតនូវយន្តការ ពិភាក្សា រវាងពលរដ្ឋ និងរដ្ឋ ដូចជា កម្មវិធីសន្ទនាមតិតាមវិទ្យុ វេទិកាពិភាក្សា ការប្រជុំរបស់សាលាក្រុង ឬខេត្ត និងគណៈវិនិច្ឆ័យពលរដ្ឋ ព្រមទាំងបង្កើត វេទិកាសម្រាប់ការចរចា និងការធ្វើសេចក្តីសម្រេចចិត្តដោយមានការចូលរួម ដូចជា ការប្រជុំជាសាធារណៈ ការចូលរួមជាគណៈកម្មការ និងដំណើរការថវិកាដោយមានការចូលរួម។

**ឆន្ទៈ និងសមត្ថភាពរបស់សង្គមស៊ីវិលក្នុងការទាមទារឱ្យមន្ត្រីរដ្ឋាភិបាលមានគណនេយ្យភាព** គឺជាកត្តា សំខាន់មួយផ្សេងទៀតក្នុងការធ្វើឱ្យគណនេយ្យភាពសង្គមអនុវត្តប្រកបដោយជោគជ័យ។ ចំណុចជាឧបសគ្គចម្បង ចំពោះបរិបទ ដែលសង្គមស៊ីវិលនៅមានភាពទន់ខ្សោយ ហើយភាពជាពលរដ្ឋរបស់ពលរដ្ឋមិនមានភាពប្រសើរ។

ចំណុចទន់ខ្សោយទាំងនេះមានៈសមត្ថភាពរបស់សង្គមស៊ីវិលរួមមាន ឯករាជ្យភាពរបស់ប្រព័ន្ធផ្សព្វផ្សាយ ក្នុងការ (ស្រាវជ្រាវ វិភាគ ធ្វើឱ្យងាយ យល់ និងផ្សព្វផ្សាយព័ត៌មាន) សមត្ថភាពរបស់ពលរដ្ឋ ក្នុងការ (ចងក្រង កៀរគរ បង្កើតជាក្រុម និងបញ្ចេញមតិជាសំឡេងរួមមួយ) ឆន្ទៈ និងលទ្ធភាព ក្នុងការជួបពិភាក្សា និងចរចាជាមួយរដ្ឋាភិបាល ព្រមទាំងអនុវត្តនូវយុទ្ធសាស្ត្រ បែបស្ថាបនា និងយកលទ្ធផលជាសំខាន់ និង សមត្ថភាពរបស់អង្គការសង្គមស៊ីវិល ក្នុងការ កសាងការគាំទ្រពីសាធារណៈ និងបង្ហាញពី ឥរិយាបទប្រកបដោយ ភាពជឿទុកចិត្ត និងគណនេយ្យភាព។ សកម្មភាពបណ្តុះបណ្តាល និងការកសាង សមត្ថភាព រួមទាំងការគាំទ្រនានា ត្រូវផ្តោតជាសំខាន់លើ សង្គស៊ីវិលដូចជា សមាគមប្រជាពលរដ្ឋ អង្គការសហគមន៍មូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាលតូចៗ ក្រុមចលនាសង្គម ប្រព័ន្ធផ្សព្វផ្សាយ និងមជ្ឈមណ្ឌលច្បាប់ដែលបំរើប្រយោជន៍សាធារណៈ ទើបអាចដោះស្រាយបញ្ហាសមត្ថភាពបាន។ កិច្ចខិតខំប្រឹងប្រែងរបស់សង្គមស៊ីវិល ក្នុងការកសាង សមត្ថភាព និងលើកកម្ពស់អភិបាលកិច្ចផ្ទៃក្នុង រួមទាំងកិច្ចខិតខំប្រឹងប្រែង

របស់រដ្ឋាភិបាល និងដៃគូរអភិវឌ្ឍន៍ក្នុងការ ការគាំទ្រ សកម្មភាពខាងលើ គឺជាចំណុចស្នូលក្នុងការលើកកម្ពស់គណនេយ្យភាពសង្គម។

**ឆន្ទៈ និងលទ្ធភាពរបស់អ្នកនយោបាយ និងមន្ត្រីសាធារណៈក្នុងការឆ្លើយតបចំពោះប្រជាពលរដ្ឋ** ជាកត្តា សំខាន់ទី៣ ក្នុងការឱ្យគណនេយ្យភាពសង្គមអនុវត្តដោយជោគជ័យ។ ផ្អែកលើមូលដ្ឋានគោលទាំងបី របស់គណនេយ្យ ភាពសង្គមគឺ ព័តិមាន កាសបញ្ចេញសំឡេងរបស់ពលរដ្ឋ និងការចរចា -ឆន្ទៈ និងលទ្ធភាពរបស់ មន្ត្រីសាធារណៈ ក្នុងការបង្ហាញនូវព័តិមាន និង ស្តាប់ និងភ្ជាប់ទំនាក់ទំនងជាមួយប្រជាពលរដ្ឋជា កត្តាសំខាន់។ មានរដ្ឋាភិបាលជាច្រើនបានអនុវត្តនូវសកម្មភាពជា ច្រើនដើម្បីពង្រឹងសមត្ថភាពរបស់ខ្លួន ក្នុងការផ្សព្វផ្សាយព័តិមាន និងភ្ជាប់ទំនាក់ទំនងជាមួយ ប្រជាពលរដ្ឋ។ សកម្មភាពទាំងនេះ ជួនកាលមានការគាំទ្រដោយ ដៃគូរអភិវឌ្ឍន៍ និងសហការជាមួយអង្គការសង្គមស៊ីវិល ដូចជា ការរៀបចំប្រព័ន្ធគ្រប់គ្រងព័តិមាន ការបណ្តុះបណ្តាលមន្ត្រី អំពីជំនាញទំនាក់ទំនង និងការសម្របសម្រួល ការប្រើនូវប្រព័ន្ធលើកទឹកចិត្ត និងការដាក់ទណ្ឌកម្ម ដើម្បីលើកកម្ពស់តម្លាភាព និងការឆ្លើយតបការអនុវត្តស្របតាមក្រមសីលធម៌វិជ្ជាជីវៈ និងការផ្សព្វផ្សាយព័តិមានអំពី គោលនយោបាយគណនេយ្យភាព ឬសិទ្ធិរបស់ពលរដ្ឋ។

កត្តាសំខាន់ចុងក្រោយគឺ គណនេយ្យភាពសង្គមទទួលរងនូវឥទ្ធិពល **នយោបាយ ច្បាប់ វប្បធម៌សង្គម និងសេដ្ឋកិច្ច**។ កត្តាទាំងនេះមានតួនាទីសំខាន់ក្នុងការកំណត់នូវរូបភាព និងលទ្ធភាពនៃជោគជ័យរបស់គណនេយ្យភាព សង្គម។ បរិយាកាសអំណោយមួយចំនួនមានសារៈសំខាន់ណាស់ចំពោះគណនេយ្យភាពសង្គម ដែលត្រូវពិចារណានិងយកចិត្តទុកដាក់មុនពេលអនុវត្ត។ ឧទាហរណ៍ គណនេយ្យភាពសង្គមអាចអនុវត្តទៅបានគឺ អាស្រ័យរបបនយោបាយបែបលទ្ធិប្រជាធិបតេយ្យ ដែលមានប្រព័ន្ធពហុបក្ស ហើយសិទ្ធិនយោបាយ និងសិទ្ធិពលរដ្ឋមានការធានា។ មាននីតិរដ្ឋ និងច្បាប់ធានានិងគាំទ្រដល់សេរីភាពព័តិមាន សារព័តិមាន ការសំដែងមតិ សមាគម។ កត្តា វប្បធម៌សង្គម និងសេដ្ឋកិច្ចក៏ជាចំណុចសំខាន់ដែរ ដូចជា ការរំពឹងទុករបស់ពលរដ្ឋ និងទំនាក់ទំនងជាមួយរដ្ឋាភិបាល ឆន្ទៈរបស់ពលរដ្ឋក្នុងការសាកសួរ និងសំដែងមតិចំពោះរដ្ឋាភិបាល សមត្ថភាព និងមធ្យោបាយរបស់សង្គមស៊ីវិលក្នុងការ រៀបចំ និងអនុវត្ត។ ទោះបីបរិយាកាសមិនសូវអំណោយផល មិនមែនមានន័យថា គណនេយ្យភាពសង្គមមិនអាចអនុវត្តបាននោះដែរ។ ហេតុនេះហើយ ត្រូវមានសកម្មភាព ឬកំណែទម្រង់នានា ដើម្បីបង្កើតបរិយាកាសអំណោយផល ដូចជាការណែនាំ ពីគតិយុត្តិស្តីពីសេរីភាពព័តិមាន ឬការសម្របសម្រួលឱ្យអង្គការមិនមែនរដ្ឋាភិបាលចុះបញ្ជី ក៏អាចធ្វើឱ្យគណនេយ្យភាពសង្គមមានប្រសិទ្ធភាព និងចីរភាពបានដែរ។

## ៥. ទំនាក់ទំនងរវាងគណនេយ្យភាពសង្គម វិមជ្ឈការ និងអភិបាលកិច្ចល្អ

ដូចដែលបានពិភាក្សាខាងលើ គណនេយ្យភាពសង្គមមានតួនាទីសំខាន់ក្នុងការធ្វើឱ្យ អភិបាលកិច្ចកាន់តែល្អប្រសើរឡើង។ ជួនកាល គណនេយ្យភាពសង្គម ជាការទាមទារឱ្យមានអភិបាលកិច្ចល្អ ដោយវាជាសកម្មភាពរបស់ប្រជាពលរដ្ឋក្នុងការទាមទារឱ្យអ្នកដឹកនាំ និងក្រុមប្រឹក្សាដែលជាប់ឆ្នោតមានគណនេយ្យភាព។ ដោយការធ្វើឱ្យមានអភិបាលកិច្ចល្អមិនមែនជាកាតព្វកិច្ចរបស់រដ្ឋាភិបាលតែម្នាក់នោះទេ។ វាតម្រូវឱ្យមានការចូលរួម ពីគណបក្សនយោបាយ រដ្ឋសភា តុលាការ ប្រព័ន្ធផ្សព្វផ្សាយ សង្គមស៊ីវិល។ ដូចនេះ វាជាសកម្មភាពរួមគ្នា រវាង ពលរដ្ឋ អ្នកដឹកនាំ និងស្ថាប័នសាធារណៈ ដើម្បីធ្វើឱ្យការផ្តល់សេវាមានភាពល្អប្រសើរឡើង។

យន្តការគណនេយ្យភាពសង្គម ទ្រទ្រង់កំណែទម្រង់រដ្ឋបាលសាធារណៈ ដើម្បីលើកកម្ពស់ការចូលរួមពីភាគីទាមទារ (ពលរដ្ឋ) ក្នុងការត្រួតពិនិត្យគណនេយ្យភាពក្នុងការផ្តល់សេវាសាធារណៈ។ យន្តការគណនេយ្យភាពសង្គមមានតួនាទីយ៉ាងសំខាន់ក្នុងវិមជ្ឈការ ដោយជួយភ្ជាប់ទំនាក់ទំនងរវាង ប្រជាពលរដ្ឋ និងរដ្ឋបាលមូលដ្ឋាន និងជំរុញឱ្យអាជ្ញាធរមូលដ្ឋាន និងអ្នកផ្តល់សេវាថ្នាក់មូលដ្ឋាន កាន់តែមានការឆ្លើយតប និងមានប្រសិទ្ធភាព។

ដូច្នេះ គណនេយ្យភាពសង្គម ជាការអនុវត្ត ឬ សកម្មភាព ដែលលើកកម្ពស់ការចូលរួមរបស់ពលរដ្ឋក្នុងដំណើរការអភិបាលកិច្ច។ ការចូលរួមរបស់ពលរដ្ឋអាចរួមចំណែកធ្វើវិមជ្ឈការមានភាពប្រសើរឡើងសំដៅលើកកម្ពស់ការផ្តល់សេវា។

## ៦. យន្តការ ឬ ឧបករណ៍គណនេយ្យភាពសង្គម

ក្រោយពីបានពិភាក្សាអំពីអត្ថប្រយោជន៍និងឥទ្ធិពលលើអភិបាលកិច្ច និង ការផ្តល់សេវា ការលើកឡើងយន្តការ/ឧបករណ៍មួយចំនួនពិតជាមានសារសំខាន់ណាស់។ យន្តការ/ឧបករណ៍ទាំងនេះត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយដោយពលរដ្ឋ CSOs សហគមន៍ព្រមទាំងបណ្តារដ្ឋាភិបាលនានានៅកម្រិតខុសៗគ្នានៃវដ្តអភិវឌ្ឍន៍ ដោយចាប់ផ្តើមពីការរៀបផែនការ និង ធ្វើការត្រួតពិនិត្យនិងវាយតម្លៃ។

**ការបោះឆ្នោត**

**ការរៀបចំគោលនយោបាយ**




រូបភាពខាងលើបង្ហាញពីទីតាំងផ្សេងៗគ្នាដែលគណនេយ្យភាពសង្គម អាចត្រូវបានអនុវត្តក្នុងខួបអភិបាលកិច្ច និង លំហសកម្មភាពដោយសង្គមស៊ីវិលឬពលរដ្ឋដែលអាចកើតឡើងក្នុងលំហណាមួយ។ ដោយចាប់ផ្តើមពីដំណើរការបោះឆ្នោតដែលជាគ្រឹះរបស់លិទ្ធិប្រជាធិបតេយ្យ ការបង្កើតគោលនយោបាយ ការរៀបចំផែនការ និងការចាត់ចែងធនធាន ការប្រើប្រាស់ធនធាន និង ចុងក្រោយគឺការផ្តល់សេវាគណនេយ្យភាពរបស់រដ្ឋគួរតែត្រូវបានធានានៅដំណាក់ណាមួយក្នុងចំណោមដំណាក់កាលទាំងអស់នេះដើម្បីធានាឱ្យបានប្រសិទ្ធិភាពអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ។